IUF Asia/Pacific

## កម្មករផ្នែកដឹកជញ្ជូនចំណីអាហារ និង អាហារវេចខ្ចប់ភ្លាម

ពេលវេលារបស់យើងមកដល់ហើយ!

នៅពេលដែលមនុស្សគ្រប់គ្នាត្រូវបានបង្ខំឲ្យស្នាក់នៅក្នុងផ្ទះដោយសារជំងឺកូវីដ-១៩ ក្រុមយើងត្រូវបានទទួលស្គាល់ថាជាកម្មករនិយោជិតដែលមានតួនាទីចាំបាច់។

ក្រុមយើងបានធ្វើ រៀបចំ និងដឹកជញ្ជូនចំណីអាហារដែលបានជួយដល់មនុស្សគ្រប់គ្នានៅក្នុងកំឡុងវិបត្តិនេះ។

យើងបានប្រថុយប្រថានសុខភាពផ្ទាល់ខ្លួនដើម្បីផ្គត់ផ្គង់ចំណីអាហារដល់មនុស្សគ្រប់រូប។

យើងបានបំពេញការងារនៅជួរមុខ។

ខណៈការអនុវត្តន៍វិធានការបង្ខំមនុស្សឲ្យស្នាក់នៅក្នុងផ្ទះត្រូវបានបញ្ចប់ ក្រុមយើងនៅតែបន្តបំពេញការងារនៅជួរមុខដដែល ដែលធ្វើឲ្យក្រុមយើងប្រឈមខ្លាំងជាមួយជំងឺកូវីដ-១៩។

ខណៈការអនុវត្តន៍វិធានការបង្ខំមនុស្សឲ្យស្នាក់នៅក្នុងផ្ទះត្រូវបានបញ្ចប់ ក្រុមយើងនៅតែជាក្រុមកម្មករនិយោជិតដែលមានភារៈកិច្ចចំបាច់

ខណៈការអនុវត្តន៍វិធានការបង្ខំមនុស្សឲ្យស្នាក់នៅក្នុងផ្ទះត្រូវបានបញ្ចប់ ក្រុមយើងគួរតែនៅបន្តទទួលបានការទទួលស្គាល់ និងការគោរព។

ការងាររបស់ក្រុមយើងគឺជាកិច្ចការចំបាច់។ ការងាររបស់ក្រុមយើងគឺជាការងារដែលមានតម្លៃ!

ការងាររបស់ក្រុមយើងគឺជាការងារពិតប្រាកដ។

យើងគួរតែទទួលបានសុវត្ថិភាពការងារ និងប្រាក់កម្រៃប្រសើរជាងនេះ។

ការលួចបន្លំប្រាក់កម្រៃត្រូវតែបញ្ឈប់។

ការងាររបស់យើងត្រូវតែមានសុវត្ថិភាពជាងនេះ ហើយសុខភាពរបស់យើងត្រូវតែទទួលបានការការពារ។

យើងត្រូវតែទទួលបានការធានារ៉ាប់រងសុខភាព និងការធានារ៉ាប់រងគ្រោះថ្នាក់ការងារ។

យើងគួរតែបានទទួលការរាក់ទាក់ប្រសើរជាងនេះពីសំណាក់ក្រុមអ្នកគ្រប់គ្រង។

យើងគួរតែបានទទួលការរាក់ទាក់ប្រសើរជាងនេះសំណាក់អតិថិជន។

នៅមុនពេលដែលមនុស្សគ្រប់គ្នាភ្លេចពីភាពចាំបាច់នៃការងាររបស់ពួកយើង។

នៅមុនពេលដែលមនុស្សគ្រប់គ្នាភ្លេចពីមធ្យោបាយដែលយើងបានរៀបចំ បម្រើ និងដឹកជញ្ជូនចំណីអាហារឲ្យគេកំឡុងពេលវិបត្តិនៃជំងឺកូវីដ-១៩។

នៅមុនពេលដែលក្រុមយើងត្រូវបានគេបំភ្លេច
សូមក្រោកឈរឡើងដើម្បីឲ្យមនុស្សគ្រប់គ្នាមើលឃើញក្រុមយើង!
សូមបន្លឺសម្លេងឡើងដើម្បីទាមទារឲ្យគេស្តាប់សម្លេងរបស់ក្រុមយើង!
សូមចូលរួមចងក្រងគ្នាឡើង!

**ពេលវេលារបស់យើងមកដល់ហើយ!**